

មករា និងរតនា ពេលទៅសាលា តែងតែជិះកង់
រៀនលេខរៀនអក្សរផ្ទង់ ពេលសរសេរត្រូវតម្រង់ ហើយរចនា ។




ឯគ្រូសុខវិញ គឺជាគោព្រៃ ជាគ្រូមត្តេយ្យ
នៅឯសាលា គាត់គឺជាគ្រូ ដែលឧស្សាហ៍
គ្រប់មុខវិជ្ជាគាត់ចេះទាំងអស់ ។



កាលខ្ញុំនៅតូច ជាសិស្សកំហូច រៀនខ្លាចសាលា
ចូលរៀនដំបូង យំនឹកម៉ាក់ប៉ា មិនដឹងម៉ោងណា
គ្រូឱ្យទៅផ្ទះ ។




អូ !!! ប្អូនដល់ម៉ោងចូលរៀនហើយ បងរតនា !
ចាស !!! ប្អូនទៅចុះ លាហើយ !
បាទ !!! ជម្រាបលា បងរតនា !



នៅក្នុងសាលា ត្រូវខំសិក្សា ក្រេបយកចំណេះ
វិជ្ជាជាស្ថាន ជាយានជំនិះ ជួយឱ្យយើងឈ្នះ
ផុតទុក្ខវេទនា ។



ពេលឆ្ងល់ខ្ញុំសួរ អ្វីគួរមិនគួរ គ្រូតែងតែឆ្លើយ ទូន្មានប្រដៅ ហើយជួយបកស្រាយ ជាហេតុធ្វើឱ្យ ខ្ញុំចង់សិក្សា ។



ជាកូនចៅល្អ
ត្រូវចេះស្តាប់គ្រូ

ត្រូវស្តាប់ពុកម៉ែ
ចេះគិតចេះគួរ
គោរពវិន័យ ។

ជាសិស្សពូកែ
ជាសិស្សគំរូ



ពេលលេងខ្ញុំចេះគិត ចែករំលែកមិត្ត បានលេងគ្រប់គ្នា  
ហើយត្រូវតែចេះ ជួយយកអាសា សប្បាយសុខា  
ទាំងអស់គ្នា ។



ត្រូវចេះគោរពសិទ្ធ
ស្រលាញ់រាប់អាន

យើងគួរចេះគិត
មិត្តទាំងប្រុសស្រី
គ្នាទើបបានល្អ ។

កុំរើសអើងអី
ចេះឱ្យតម្លៃ



ពេលដល់ម៉ោងទៅផ្ទះ យើងត្រូវសំពះ ជម្រាបលាគ្រូ
នេះហើយគឺជា កុមារគំរូ ចេះគោរពគ្រូ
គោរពចាស់ទុំ ។



នៅពេលទៅដល់ផ្ទះ គោរពសំពះ តាមក្បួនតម្រា
កូនមកវិញហើយ មកពីសាលា គោរពម៉ាក់ប៉ា
តាមប្រពៃណី ។



ចូរកូនចៅខ្មែរទាំងប្រុសស្រី កុំភ្លេចប្រពៃណីពីដូនតា
ត្រូវថែវប្បធម៌ជាតិខេមរា ខ្មែរយើងថ្លៃថ្លាគង់វង្សអើយ ។




# កុមារគំរូ

អ្នកនិពន្ធ៖ TukTuk

អ្នកគំនូរ៖ ហ៊ិន ឆវិន

គំនូរជីវចល

ធនធានបង្រៀន

អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

TUKTUK

Rotary